ព្រះរាជាណាចក្រកម្ពុជា

សាលាឧទ្ធរណ៍ភ្នំពេញ                    ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ

លេខ::៦៦/២០-០១-០៦

# សាលដីកា

លេខ:១៤៣"ខ"/២០-១២-០៧

ក្នុងនាមប្រជារាស្ត្រខ្មែរ

សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៥-១២-២០០៧ ដោយមានសមាសភាព ដូចខាងក្រោមៈ

**ក្រុមប្រឹក្សាជំនុំជម្រះ**

១- លោក [redacted] ជាប្រធាន

២- លោក [redacted] ជាចៅក្រម

៣- លោក [redacted] ជាចៅក្រម

**តំណាងអយ្យការ**

ឯកឧត្តម [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

១- ជនជាប់ចោទឈ្មោះ [redacted]ចំរើន ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ មុខរបរសិស្សថ្នាក់ទី១១ កើតនៅសង្កាត់បឹងសាឡាង ខណ្ឌទួលគោក ក្រុងភ្នំពេញ ទីលំនៅ[redacted] សង្កាត់បឹងសាឡាង ខណ្ឌទួលគោក ក្រុងភ្នំពេញ ឪពុកឈ្មោះ[redacted]"រ" ម្តាយឈ្មោះ[redacted] "រ" នៅលើវ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី០៤-៧-២០០៥ ឃុំខ្លួនថ្ងៃទី១២-៧-២០០៥ បច្ចុប្បន្ននៅក្នុងឃុំ "ម១" មានមេធាវីលោកស្រី [redacted] ។

២- ជនជាប់ចោទឈ្មោះ [redacted] សុខៃ ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ មុខរបរគ្មាន កើតនៅភូមិតូច ឃុំក្រាំងស្វាយ ស្រុកឈូក ខេត្តកំពត ទីលំនៅមុនចាប់ខ្លួនផ្ទះលំ [redacted] ខណ្ឌទួលគោក ក្រុងភ្នំពេញ ឪពុកឈ្មោះ[redacted]"រ" ម្តាយឈ្មោះ [redacted]"រ" នៅលើវ បច្ចុប្បន្ននៅពន្ធនាគារ ម១ ទោសពីមុនមាន "ធ្លាប់ជាប់ពន្ធនគារ P J នៅឆ្នាំ១៩៩៩ ចំនួន៤ឆ្នាំ៦ខែ ពីបទ ឆក់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១៧-៧-១៩៩៩ ដោះលែងថ្ងៃទី២០-០១-០៤, **លើកទី** ២ ក្នុងសាលក្រមលេខ ០៧ "គ" ចុះថ្ងៃទី ២៧-០១-២០០៥ ជាប់ពីបទ ប្លន់ កាលពីថ្ងៃទី១៧-៧-២០០៤ សំរេចដាក់ពន្ធនាគារ៥ឆ្នាំ គេចខ្លួន, លើកទី ៣ ចាប់ខ្លួនថ្ងៃទី០៤-៧-២០០៥ ឃុំខ្លួនថ្ងៃទី១២-៧-២០០៥ ។

៣- ជនជាប់ចោទឈ្មោះ [redacted]សារឹន ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ មុខរបរសិស្ស កើតនៅសង្កាត់

ទឹកល្អក់១ ខណ្ឌទួលគោក ក្រុងភ្នំពេញ ទីលំនៅមុនចាប់ខ្លួនផ្ទះ[redacted] ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី០៥-៧-២០០៥ ឃុំខ្លួនថ្ងៃទី២២-៧-២០០៥ បច្ចុប្បន្ននៅក្នុងឃុំ "PJ" មានមេធាវី លោក[redacted] ស៊ីថាន។

**៤- ជនជាប់ចោទឈ្មោះ** [redacted] **ចិន្តាម៉ារឌី** ភេទប្រុស អាយុ១៧ឆ្នាំ ជាតិខ្មែរ មុខរបរសិស្សថ្នាក់ទី១២ កើតនៅភូមិបន្ទាយចាស់ ឃុំបន្ទាយចាស់ ស្រុកសៀមរាប ខេត្តសៀមរាប ទីលំនៅមុនចាប់[redacted] សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី ០៤-៧-២០០៥ ឃុំខ្លួនថ្ងៃទី១២-៧-២០០៥ បច្ចុប្បន្ននៅក្នុងឃុំ "ម១" មានមេធាវី លោក[redacted]ហៃ។

<u>**ត្រូវចោទពីបទៈ**</u> " ប្លន់ " ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៩-៦-២០០៥ តាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

**ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ**[redacted] សំបូរ ភេទស្រី អាយុ២៤ឆ្នាំ ជាតិខ្មែរ មុខរបរបុគ្គលិកសណ្ឋាគារសេរាតោន ទីលំនៅសព្វថ្ងៃ[redacted] ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ។

តាមបណ្តឹងឧទ្ធរណ៍លេខ៥៦ "ប" ចុះថ្ងៃទី ០៧-១០-២០០៥ របស់ជនជាប់ចោទឈ្មោះ [redacted] សាវឹន បណ្តឹងឧទ្ធរណ៍លេខ៥៨ "ប" ចុះថ្ងៃទី ១២-១០-២០០៥ របស់ជនជាប់ចោទឈ្មោះ [redacted]ចំរើន, បណ្តឹងឧទ្ធរណ៍លេខ ៥៩ "ប" ចុះថ្ងៃទី១៩-១០-២០០៥ របស់ជនជាប់ចោទឈ្មោះ [redacted]ចិន្តាម៉ារឌី, បណ្តឹងឧទ្ធរណ៍លេខ៦៦ "ប" ចុះថ្ងៃទី០២-១១-២០០៥ របស់ជនជាប់ចោទឈ្មោះ[redacted]សុខៃ ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខៈ៩៩ "ប" ចុះថ្ងៃទី១៥-៩-២០០៥ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចទាំងមូល។

<u>**ដំណើររឿងមានដូចតទៅៈ**</u>

តាមពាក្យបណ្តឹងចុះថ្ងៃទី ០៩-៦-២០០៥ របស់ឈ្មោះ ខាត់ សំបូរ ថាៈ កាលពីថ្ងៃទី០៩-៦-២០០៥ ម៉ោង៥ល្ងាច ខ្លួនជិះម៉ូតូម៉ាកសេ១២៥ ពណ៌ខ្មៅ២០០៥. លេខតួ៨០៧៨៤៤៧. លេខម៉ាស៊ីន៨០៧៨៤៤៧. ផ្លាកលេខ១ដេ៨៣៣៧. ម្នាក់ឯង ខ្លួនជិះមកដល់មុខក្រសួងសាធារណៈការ និងដឹកជញ្ជូន ផ្លូវព្រះនរោត្តម ជាប់របងរតនាគារ មានជនល្មើស៥នាក់ជិះម៉ូតូ៣គ្រឿង កៀរពីក្រោយឱ្យខ្លួនឈប់ អ្នកជិះម៉ូតូម៉ាកវីវ៉ាដកកាំភ្លើងខ្លីម៉ាកកា៥៩ ភ្ជង់គំរាម ហើយបក្សពួកជិះម៉ូតូម៉ាកសេ១២៥ ចុះពីលើម៉ូតូច្របាច់ក និងទាញសក់ខ្លួន រុញចេញពីម៉ូតូ ពួកវាយកម៉ូតូទៅបាត់. ម៉ូតូខ្លួនតំលៃ ១១៤៥ដុល្លា សមត្ថកិច្ចឱ្យខ្លួនមើលមុខ ខ្លួនស្គាល់មុខអ្នកភ្ជង់ខ្លួន នគរបាលប្រាប់ថាឈ្មោះ[redacted] សុខខៃ។ សំណូមពរទាមទារសំណងថ្លៃម៉ូតូ និងផ្តន្ទាទោសជនល្មើសតាមច្បាប់ ។

- បានឃើញចម្លើយជនជាប់ចោទឈ្មោះ[redacted]សុខខៃ ឆ្លើយថា នៅថ្ងៃទី ១៧-៧-១៩៩៩ ត្រូវសមត្ថកិច្ចចាប់ខ្លួនដាក់គុក៤ឆ្នាំ ពីបទ ឆក់ ដោះលែងនៅថ្ងៃទី ២០-០១-២០០៤. ថ្ងៃទី១១-៧-២០០៤ សមត្ថកិច្ចចោទថាខ្លួនប្លន់ ហើយតុលាការសំរេចតាមសាលក្រមកំបាំងមុខលេខ ០៧ "គ" ចុះថ្ងៃទី ២៧-០១-២០០៥ សំរេចដាក់គុក៥ឆ្នាំ "គេចខ្លួន" ខ្លួនមិនប្តឹងទាស់ ឬ ឧទ្ធរណ៍ទេ សុខចិត្តទទួលទោស ។នៅថ្ងៃទី០៩-៦-២០០៥ ម៉ោង៥ល្ងាច នៅមុខក្រសួងសាធារណៈការ មានស្រីម្នាក់

ជិះម៉ូតូសេ១២៥ ពួកខ្លួន៥នាក់ [redacted] ចំរើន បើកម៉ូតូវីវ៉ាឌុបខ្លួន [redacted] ចិន្តាម៉ារឌី បើកម៉ូតូហុងដាសេ១២៥ ឌុប [redacted] សាវីន, [redacted] ស្រេង ជិះម៉ូតូណៃខ្មៅ២០០៥ ។ [redacted] ស្រេង កៀវស្រីនោះឱ្យអែបខាង ខ្លួនយកកាំភ្លើងកា៥៩ ភ្ជង់, [redacted] សាវីន អ្នកចុះយកម៉ូតូជនរងគ្រោះ. ក្រោយមកខ្លួនប្រគល់ម៉ូតូនោះឱ្យឈ្មោះ [redacted] ចំរើន យកទៅលក់. ខ្លួនមិនបានចំណែកទេ។ ចំណែកនៅសវនាការ [redacted] សុខខៃ ឆ្លើយថា កាលពីថ្ងៃទី០៩-៦-២០០៥ ខ្លួន និង [redacted] ស្រេង ប្លន់តែពីរនាក់ គឺ [redacted] ស្រេង ជាអ្នកជិះម៉ូតូកៀវ ស្រីនោះ ខ្លួនអ្នកភ្ជង់ ម្ចាស់រត់ចោល ខ្លួនឡើងជិះម៉ូតូចេញ។ [redacted] ចំរើន, [redacted] សាវីន, [redacted] ចិន្តាម៉ារឌី ពុំបានប្លន់ទេ។

- បានឃើញចម្លើយជនជាប់ចោទឈ្មោះ [redacted] ស្រេង ឆ្លើយថា: កាលពីថ្ងៃទី០៩-៦-២០០៥ ម៉ោង១៧ គ្នាខ្លួន ៥នាក់ ម៉ូតូ៣ ដល់មុខក្រសួងសាធារណការ ផ្លូវនរោត្តម ខ្លួនជិះកៀវស្រីម្នាក់ឱ្យឈប់ [redacted] សុខខៃ ដកអាវុធភ្ជង់ជនរងគ្រោះ ភ័យរត់ចោលម៉ូតូ ខ្លួនឱ្យ [redacted] សាវីន យកម៉ូតូជិះគេចខ្លួន។ ខ្លួនជំពាក់លុយ សៀង ចំរើន ១៥០ដុល្លា [redacted] សុខខៃ ជំពាក់ [redacted] ចំរើន ១៥០ដុល្លា ក៏កាត់ម៉ូតូប្លន់បានឱ្យ [redacted] ចំរើន តែម្តង ។ នៅសវនាការឈ្មោះ [redacted] ស្រេង ឆ្លើយថា: នៅថ្ងៃទី ០៩-៦-០៥ ខ្លួនជិះកៀវស្រីម្នាក់ [redacted] សុខខៃ ភ្ជង់ស្រីនោះ១រត់ចោលម៉ូតូ [redacted] សុខខៃ ចុះយកម៉ូតូជិះចេញ ក្រោយមកខ្លួន និង [redacted] សុខខៃ យកម៉ូតូដែលប្លន់បានទៅលក់នៅកំពង់សោម [redacted] សុខខៃ ចែកខ្លួន ៣០០ដុល្លា ។ ការប្លន់នេះមានតែខ្លួន និង [redacted] សុខខៃប៉ុណ្ណោះ ។

- បានឃើញចម្លើយជនជាប់ចោទឈ្មោះ [redacted] សាវីន ឆ្លើយថា: នៅថ្ងៃទី០៩-៦-២០០៥ ខ្លួនពុំបានចូលរួមប្លន់ទេ ខ្លួនកំពុងតែលេងហ្គេមនៅសាលាសន្ធរមុខ ជាមួយ [redacted] ហេងហាំង ខ្លួនលេងពីម៉ោង៨ព្រឹក ដល់ម៉ោង៦-៧ យប់ ។

- បានឃើញចម្លើយជនជាប់ចោទឈ្មោះ [redacted] ចំរើន ឆ្លើយថា: កាលពីថ្ងៃទី០៩-៦-២០០៥ ម៉ោង៤ ល្ងាច ពួកខ្លួន ៥នាក់ជិះមកដល់មុខនាឡិកាវត្តភ្នំឃើញស្រីម្នាក់ ពួកខ្លួនជិះតាមស្រីនោះឱ្យឈប់ [redacted] សុខខៃ ភ្ជង់ម្ចាស់ម៉ូតូ [redacted] សាវីន ចុះពីលើម៉ូតូដណ្តើមម៉ូតូពីស្រីនោះជិះទៅ។ ថ្ងៃទី១០-៦-២០០៥ ម៉ោង៨ [redacted] សាវីន, [redacted] ស្រេង, [redacted] សុខខៃ ជួបគ្នានៅសន្ធរម៉ុក ចែកលុយគ្នាម្នាក់១៥០ដុល្លា ជាលុយខ្លួនចេញឱ្យវា ព្រោះម៉ូតូប្លន់បាន ខ្លួនទុកជិះខ្លួនឯង។ នៅសវនាការឈ្មោះ [redacted] ចំរើន ឆ្លើយថា: ថ្ងៃទី០៩-៦-២០០៥ ខ្លួនមិនបានប្លន់ទេ ។

- បានឃើញ ចម្លើយជនជាប់ចោទឈ្មោះ [redacted] ចិន្តាម៉ារឌី ឆ្លើយពេលសវនាការថា: ខ្លួនមិនបានប្លន់ នៅថ្ងៃទី ០៩-៦-២០០៥ នោះទេ, ចម្លើយនៅនគរបាលសុំបដិសេធចោល ដោយនគរបាលវាយធ្វើទារុណកម្មលើខ្លួន។

**- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៩៩ "ថ" ចុះថ្ងៃទី១៥-៩-២០០៥ របស់សាលាដំបូងក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :**

១- ផ្តន្ទាទោសឈ្មោះ [redacted] សុខខៃ ភេទប្រុស អាយុ២៦ឆ្នាំ ដាក់ពន្ធនាគារចំនួន០៧ឆ្នាំ "ប្រាំពីរឆ្នាំ" គិតចាប់ពីថ្ងៃអនុវត្តចប់នៃទោសដែលមានក្នុងសាលក្រមមុន។

២- ផ្តន្ទាទោសឈ្មោះ [redacted] ស្រេង ភេទប្រុស អាយុ២៤ឆ្នាំ ដាក់ពន្ធនាគារចំនួន០៧ឆ្នាំ "ប្រាំពីរឆ្នាំ" គិតចាប់ពីថ្ងៃ ចាប់ខ្លួន ០៤-៧-២០០៥ ។

៣- ផ្តន្ទាទោសឈ្មោះ [redacted] សាវីន ភេទប្រុស អាយុ១៨ឆ្នាំ ដាក់ពន្ធនាគារចំនួន០៥ឆ្នាំ "ប្រាំឆ្នាំ" គិតចាប់ពីថ្ងៃ ចាប់ខ្លួន ០៥-៧-២០០៥ ។

៤- ផ្ដន្ទាទោសឈ្មោះ [redacted] ចិន្ដាម៉ារឌី ភេទប្រុស អាយុ១៨ឆ្នាំ ដាក់ពន្ធនាគារចំនួន០៥ឆ្នាំ "ប្រាំឆ្នាំ" គិតចាប់ពីថ្ងៃ ចាប់ខ្លួន ០៤-៧-២០០៥ ។

៥- ផ្ដន្ទាទោសឈ្មោះ [redacted] ចំរើន ភេទប្រុស អាយុ១៩ឆ្នាំ ដាក់ពន្ធនាគារចំនួន០៥ឆ្នាំ "ប្រាំឆ្នាំ" គិតចាប់ពីថ្ងៃ ចាប់ខ្លួន ០៤-៧-២០០៥ ។

ទាំងប្រាំនាក់នេះផ្ដន្ទាទោសពីបទ ប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៩-៦-២០០៥ តាមបញ្ញត្តិមាត្រា៦ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

ឱ្យជនជាប់ចោទឈ្មោះ [redacted] សុខខៃ, [redacted] ស្រេង, [redacted] សាវីន, [redacted] ចំរើន, [redacted] ចិន្ដាម៉ារឌី រួមគ្នាចេញសង តំលៃម៉ូតូ ០១គ្រឿងចំនួន ១១៤៥ដុល្លា "មួយពាន់មួយរយសែសិបប្រាំដុល្លាអាមេរិក" ឱ្យទៅជនរងគ្រោះឈ្មោះ [redacted] សំបូរ ក្នុងករណីរឹងរូសពុំព្រមសង ត្រូវដាក់គុកបង្ខំរូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៦- លើកលែងឱ្យរួចខ្លួន ពីការចោទប្រកាន់លើឈ្មោះ [redacted] សត្យា ភេទប្រុស អាយុ២២ឆ្នាំ ពីបទ សមគំនិតក្នុង អំពើប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៩-៦-២០០៥ ។

៧- លើកលែងឱ្យរួចខ្លួន ពីការចោទប្រកាន់លើឈ្មោះ [redacted] ហេងហាំង ភេទប្រុស អាយុ២៣ឆ្នាំ ពីបទ សមគំនិតក្នុងអំពើប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៩-៦-២០០៥ ។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទទាំង៧នាក់ "ប្រាំពីរនាក់" ចំពោះ មុខមេធាវីការពារជនជាប់ចោទ កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី បើកសិទ្ធិប្ដឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញបណ្ដឹងឧទ្ធរណ៍លេខ៥៦ "វ" ចុះថ្ងៃទី ០៧-១០-២០០៥ របស់ជនជាប់ចោទឈ្មោះ [redacted] សាវីន, បណ្ដឹងឧទ្ធរណ៍លេខ៥៨ "វ" ចុះថ្ងៃទី ១២-១០-២០០៥ របស់ជនជាប់ចោទឈ្មោះ [redacted] ចំរើន, បណ្ដឹងឧទ្ធរណ៍លេខ ៥៩ "វ" ចុះថ្ងៃទី១៩-១០-២០០៥ របស់ជនជាប់ចោទឈ្មោះ [redacted] ចិន្ដាម៉ារឌី, បណ្ដឹងឧទ្ធរណ៍លេខ៦៦ "វ" ចុះថ្ងៃទី០២-១១-២០០៥ របស់ ជនជាប់ចោទឈ្មោះ [redacted] សុខៃ ប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ:៩៩ "វ" ចុះថ្ងៃទី១៥-៩-២០០៥ របស់តុលាការ ក្រុងភ្នំពេញ ត្រង់ចំណុចទាំងមូល ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍ ។

- បានឃើញរបាយការណ៍រឿងចុះថ្ងៃទី០៨-៨-២០០៧ របស់ចៅក្រមសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

ចៅក្រមអានរបាយការណ៍រឿង

**- ជនជាប់ចោទឈ្មោះ [redacted] សុខខៃ** ឆ្លើយថា : ខ្លួនមិនសុខចិត្តនឹងតុលាការក្រុងភ្នំពេញ កាត់ទោសឱ្យខ្លួនមិន សមរម្យ ចំពោះអំពើប្លន់នៅថ្ងៃទី០៩-៦-២០០៥ ខ្លួនបានប្រព្រឹត្តមែន, ខ្លួនជិះម៉ូតូពីរនាក់ [redacted] ស្រេង ឃើញជនរងគ្រោះជិះម៉ូតូ ខ្លួនជាអ្នកភ្ជង់ ហើយខ្លួនចុះយកម៉ូតូ គឺមានតែខ្លួន និងឈ្មោះ [redacted] ស្រេង ពីរនាក់ដែលបានធ្វើសកម្មភាពប្លន់ ហើយពេល ធ្វើសកម្មភាព [redacted] ចំរើន, [redacted] ចិន្ដាម៉ារឌី មិនបានចូលរួមជាមួយខ្លួនទេ ឯចម្លើយនៅប៉ូលីសគឺមានការបង្ខិតបង្ខំពីប៉ូលិស,

ឈ្មោះ[redacted]សាវីន មិនបានចូលរួមទេ ហើយខ្លួនមិនស្គាល់ឈ្មោះ [redacted] សាវីន ទេ។ ពីមុនខ្លួនធ្លាប់ធ្វើសកម្មភាពប្លន់ចំនួន ៤ ដ បានសំរេចទាំង៤ លើក កាំភ្លើងជារបស់ឈ្មោះ [redacted]ប្រុស ។ សំណូមពរសុំជួយបន្ធូរបន្ថយទោស ។

- ជនជាប់ចោទឈ្មោះ [redacted] សាវីន ឆ្លើយថា : ចំពោះការចោទប្រកាន់របស់អយ្យការនៅតុលាការក្រុ ខ្លួនមិនទទួលស្គាល់ទេ ព្រោះខ្លួនមិនបានប្រព្រឹត្តទេ ។ សំណូមពរសុំលើកលែងចោទប្រកាន់ ។

- ជនជាប់ចោទឈ្មោះ [redacted] ចំរើន ឆ្លើយថា : រាល់ចម្លើយដែលបានឆ្លើយនៅប៉ូលីស និងនៅអយ្យការ គឺ ចម្លើយបង្ខិតបង្ខំ ខ្លួនសុំបដិសេធ ឯចម្លើយនៅចៅក្រមស៊ើបខ្លួនទទួលស្គាល់ ។ ខ្លួនមិនបានប្រព្រឹត្តទេ ពេលកើតហេតុខ្លួនន សាលាជាមួយសង្សា ខ្លួនមិនបានប្លន់គេទេ, ខ្លួនអត់បានទទួលចំណែកទេ, ប៉ូលីសចាប់ខ្លួនខ្ញុំ ដោយគ្មានដីកាចាប់ខ្លួនទេ សំណូមពរ សុំលើកលែងចោទប្រកាន់ ។

- ជនជាប់ចោទឈ្មោះ [redacted] ចិន្តាម៉ារឌី ឆ្លើយថា : ខ្លួនមិនបានប្រព្រឹត្តទេ ឯចម្លើយដែលខ្លួនឆ្លើយនៅប៉ូលី គឺមានការបង្ខំ ខ្លួនសុំបដិសេធ, ខ្លួនស្គាល់

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

យោងតាមការសួរដេញដោលបានបញ្ជាក់ថា ជនជាប់ចោទទាំងបួននាក់បានឆ្លើយនៅតុលាការក្រុងមានការ ស៊ីសង្វាក់គ្នា ដូច្នេះសុំតម្កល់សាលក្រមតុលាការក្រុង ។

## សេចក្តីសន្និដ្ឋានរបស់មេធាវី [redacted] រ៉ែម

សូមលោកប្រធានធ្វើការបន្ធូរបន្ថយទោសដល់កូនក្តីខ្លួន[redacted]ចិន្តាម៉ារឌី ដោយអនុគ្រោះ ហើយចំពោះអំពើប្រព្រឹ នៅថ្ងៃទី ០៩-៦-២០០៥ ឈ្មោះ [redacted]សុខខៃ បានឆ្លើយថា ខ្លួនបានប្រព្រឹត្តតែពីរនាក់ឈ្មោះ [redacted] ស្រេង នេះបញ្ជាក់ឱ្យឃើញថ កូនក្តីខ្លួន ពុំបានចូលរួមការប្រព្រឹត្តនេះទេ ដូចនេះ សូមលោកប្រធានធ្វើការលើកលែងទោសដល់កូនក្តីខ្លួន[redacted]ចិន្តាម៉ារឌី ។

## សេចក្តីសន្និដ្ឋានរបស់មេធាវី[redacted]ផាវី

តាមចម្លើយជនជាប់ចោទឈ្មោះ[redacted] សុខខៃ នៅពេលនេះបញ្ជាក់ថាកូនក្តីខ្លួន[redacted] ចំរើន មិនបានចូលរួមធ្វើ សកម្មភាពប្លន់ កាលពីថ្ងៃទី០៩-៦-២០០៥ ទេ សូមលោកប្រធានធ្វើការលើកលែងចោទកូនក្តីខ្លួន[redacted] ចំរើន ។

## សេចក្តីសន្និដ្ឋានរបស់មេធាវី ស៊ឹម ស៊ីផាន

ឆ្លងកាត់ការសិក្សាសំណុំរឿង និងការសួរដេញដោល កូនក្តីខ្លួន [redacted] សាវីន គឺពាក់ពន្ធ័នឹងការចាប់. ការចោទ គឺមិនមានភាពយុត្តិធម៌ទេ ហើយចម្លើយនៅប៉ូលីសសុំតុលាការពិនិត្យ និង ចម្លើយនៅអយ្យការ. នៅចៅក្រមស៊ើប សូមឱ្យតុលាកា ពិចារណាផងដែរ កូនក្តីខ្លួនមិនមានសាក្សីណាមួយបញ្ជាក់ថា បានចូលរួមប្រព្រឹត្តនោះទេ សំណូមពរសុំឱ្យ[redacted] សាវីន រួចផុតពីកា ចោទប្រកាន់ ។

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

## សាលាឧទ្ធរណ៍ភ្នំពេញយល់ឃើញថាៈ

-យល់ឃើញថាៈ បណ្តឹងឧទ្ធរណ៍លេខ៥៦ "ឋ" ចុះថ្ងៃទី០៧-១០-២០០៥ របស់ជនជាប់ចោទឈ្មោះ [redacted] សាវីនៈ បណ្តឹងឧទ្ធរណ៍លេខ៥៨ "ឋ" ចុះថ្ងៃទី ១២-១០-២០០៥ របស់ជនជាប់ចោទឈ្មោះ [redacted] ចំរើន, បណ្តឹងឧទ្ធរណ៍លេខ ៥៩ "ឋ" ចុះថ្ងៃទី១៩-១០-២០០៥ របស់ជនជាប់ចោទឈ្មោះ [redacted] ចិន្តាម៉ារឌី . បណ្តឹងឧទ្ធរណ៍លេខ៦៦ "ឋ" ចុះថ្ងៃទី០២-១១-២០០៥ របស់ជនជាប់ចោទឈ្មោះ [redacted] សុខៃ ធ្វើឡើងនៅក្នុងកំណត់ច្បាប់ .

-យល់ឃើញថាៈ ជនជាប់ចោទថា បក្សពួកខ្លួនមានចំនួន៥នាក់ បានធ្វើសកម្មភាពប្លន់ កាលពីថ្ងៃទី០៩-៦-២០០៥ គឺឈ្មោះ [redacted] [redacted] ខៃ. [redacted] ស្រេង. [redacted] សាវីន, [redacted] ចិន្តាម៉ារឌី និង [redacted] ចំរើន នៅថ្ងៃកើតហេតុនោះ ឈ្មោះ [redacted] ចំរើន បើកម៉ូតូវីវ៉ា សេរី២០០៤ ឌុប [redacted] សុខខៃ . [redacted] ចិន្តាម៉ារឌី បើមម៉ូតូហុងដាសេ១២៥ ឌុប [redacted] សាវីន. [redacted] ស្រេង ជិះម៉ូតូពណ៌ខ្មៅ ២០០៥ ជិះកៀរជនរងគ្រោះហើយ [redacted] សុខខៃ កាន់កាំភ្លើងកា៥៩ ភ្ជង់. [redacted] សាវីន ជាអ្នកយកម៉ូតូជនរងគ្រោះជិះចេញគេចខ្លួន ក្រោយមកប្រគល់ម៉ូតូនោះឱ្យទៅឈ្មោះ [redacted] ចំរើន យកទៅលក់ ។

ដោយឡែក ជនជាប់ចោទឈ្មោះ [redacted] ចិន្តាម៉ារឌី បានឆ្លើយប្រហាក់ប្រហែលនេះដែរ តែបានបញ្ជាក់ថា ដោយឃើញសកម្មភាពដូច្នេះរបស់ជនជាប់ចោទទាំងនោះ ខ្លួនក៏ជិះម៉ូតូគេចចេញពីពួកវា ហើយតាំងពីពេលនោះមក ពួកវាមិនដែលជួបខ្លួនទេ ហើយពួកវាយកម៉ូតូទៅលក់នៅឯណា បានតម្លៃប៉ុន្មាន ក៏ខ្លួនមិនបានដឹងដែរ ។

-យល់ឃើញថាៈ មានពិរុទ្ធលើជនជាប់ចោទពីបទ "ប្លន់"ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៩-៦-២០០៥ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពី ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

- យល់ឃើញថាៈ តាមសៀវភៅបញ្ជាក់កំណើតលេខ ៦៤.២០០៤ ចុះថ្ងៃទី០៦-១២-២០០៤ ឈ្មោះ [redacted] ចិន្តាម៉ារឌី កើតនៅថ្ងៃទី១៩-៧-១៩៨៨ . ដូច្នេះ បើគិតមកត្រឹមថ្ងៃទី០៩-៦-២០០៥ ជាកាលបរិច្ឆេទបទល្មើសកើតឡើង ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ចិន្តាម៉ារឌី នេះ ទើបតែមានអាយុបាន១៧ឆ្នាំ ១០ខែ ២០ថ្ងៃ ប៉ុណ្ណោះ ។ ដូច្នេះ អាចកំណត់បានច្បាស់ថា នៅពេលប្រព្រឹត្តបទល្មើស ជនជាប់ចោទរូបនេះ ស្ថិតក្នុងភាពជាអនិតិជន អាយុក្រោម១៨ឆ្នាំ។ ហេតុនេះសាលាឧទ្ធរណ៍ គួរពិចារណា តាមមាត្រា៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ។

-យល់ឃើញថាៈ សាលក្រមព្រហ្មទណ្ឌលេខ៩៩ "ឋ" ចុះថ្ងៃទី១៥-៩-២០០៥ របស់សាលាដំបូងក្រុងភ្នំពេញ សម្រេចត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ វៀរលែងតែចំណុចទី៤ ស្តីពីកម្រិតទណ្ឌកម្មលើជនជាប់ចោទឈ្មោះ [redacted] ចិន្តាម៉ារឌី គួរកែប្រែឱ្យបានសមស្រប ដោយហេតុអនិតិភាព ដូចយល់ឃើញខាងលើ ក្រៅពីនេះ គួររក្សាទុកនៅដដែល ។

## ហេតុដូចនេះវិនិច្ឆ័យសេចក្តី

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ៥៦ "ឋ" ចុះថ្ងៃទី ០៧-១០-២០០៥ របស់ជនជាប់ចោទឈ្មោះ [redacted] សាវីន, បណ្តឹងឧទ្ធរណ៍លេខ៥៨ "ឋ" ចុះថ្ងៃទី ១២-១០-២០០៥ របស់ជនជាប់ចោទឈ្មោះ [redacted] ចំរើន, បណ្តឹងឧទ្ធរណ៍លេខ

៥៩ "ឋ" ចុះថ្ងៃទី ១៩-១០-២០០៥ របស់ជនជាប់ចោទឈ្មោះ [redacted] ចិន្តាម៉ារឌី, និងបណ្ដឹងឧទ្ធរណ៍លេខ៦៦ "ឋ" ចុះថ្ងៃទី ០៤-១១-២០០៥ របស់ជនជាប់ចោទឈ្មោះ [redacted] សុខៃ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ .

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៩៩ "ឋ" ចុះថ្ងៃទី ១៥-៩-២០០៥ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការ ដោយគ្រាន់តែកែប្រែ កម្រិតទណ្ឌកម្មលើជនជាប់ចោទឈ្មោះ [redacted] ចិន្តាម៉ារឌី ពី៥ឆ្នាំ "ប្រាំឆ្នាំ" មកជា២ឆ្នាំ ៦ខែ "ពីរឆ្នាំប្រាំមួយខែ" វិញ ក្រៅពីនេះរក្សាទុកនៅដដែល ។

តាមមាត្រា៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងអនុសញ្ញាអន្តរជាតិស្ដីពីសិទ្ធិកុមារ ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ០៥-១២-២០០៧ ចំពោះមុខជនជាប់ចោទ, មេធាវីការពារជនជាប់ចោទ កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី, ប្រកាសជាសាធារណៈនៅថ្ងៃទី២០-១២-២០០៧ កំបាំងមុខជនជាប់ចោទ, មេធាវីការពារជនជាប់ចោទ, តែទុកជាចំពោះមុខ, កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី . បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់ចំពោះមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និង ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និង ចាត់កំលាំងប្រដាប់អាវុធគ្រប់ថ្នាក់គ្រប់ជំនាញ ជួយសហការអនុវត្តសាលដីកានេះឱ្យបានសម្រេច ហើយមានចំណាត់ការត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

..........................................................................................................................................

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

[redacted]

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី ១០ ខែ ៥ ឆ្នាំ ២០១៤
ក្រឡាបញ្ជី